ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ១៩៤១០ អពដ

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៦

# សេចក្ដីណែនាំ
## ស្ដីពី
## ការអនុវត្តកាតព្វកិច្ចពន្ធកាត់ទុកចំពោះអាជីវកម្មក្នុងវិស័យបញ្ចាំងខ្សែភាពយន្ត និងអាជីវកម្មជួលអចលនទ្រព្យបន្ត

អនុលោមតាមមាត្រា ២៥ (ថ្មី) និងមាត្រា ២៦ (ថ្មី) នៃច្បាប់ស្ដីពីសារពើពន្ធ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងប្រកាសស្ដីពីពន្ធលើប្រាក់ចំណេញ លេខ ១០៥៩ សហវ.ប្រក.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធប្រកបដោយប្រសិទ្ធភាព តម្លាភាព និងស័ក្តិសិទ្ធិភាព អគ្គនាយកដ្ឋានពន្ធដារ សូមធ្វើការណែនាំអំពីការអនុវត្តកាតព្វកិច្ចពន្ធកាត់ទុកចំពោះអាជីវកម្មក្នុងវិស័យបញ្ចាំងខ្សែភាពយន្ត និងអាជីវកម្មជួលអចលនទ្រព្យបន្ត ដូចខាងក្រោម÷

### ១. អំពីពន្ធកាត់ទុកចំពោះអាជីវកម្មក្នុងវិស័យបញ្ចាំងខ្សែភាពយន្ត

#### ក. សហគ្រាសផលិតកម្មភាពយន្តក្នុងស្រុក

សហគ្រាសផលិតកម្មភាពយន្តក្នុងស្រុក ត្រូវទទួលបានការលើកទឹកចិត្តអនុញ្ញាតឱ្យព្យួរទុកការអនុវត្តពន្ធកាត់ទុក ១៥% លើសួយសារនៃទ្រព្យអរូបី (ការផ្ដល់សិទ្ធិបញ្ចាំងខ្សែភាពយន្ត) សម្រាប់រយៈពេល ០៣ ឆ្នាំ រហូតដល់ដំណាច់ឆ្នាំ២០១៨។ ការព្យួរទុកអនុវត្តពន្ធកាត់ទុកខាងលើនេះ អនុញ្ញាតបានក្នុងលក្ខខណ្ឌដែលសហគ្រាសផលិតកម្មភាពយន្តក្នុងស្រុក បានបំពេញកាតព្វកិច្ចរបស់ខ្លួនដូចខាងក្រោម÷

- ចុះបញ្ជីពន្ធដារនៅរដ្ឋបាលសារពើពន្ធ
- ដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធប្រចាំខែ ប្រចាំឆ្នាំ និងបង់ប្រាក់ពន្ធទៅតាមទម្រង់ពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់
- កាន់កាប់បញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវ ស្របតាមច្បាប់ជាធរមាន។

ដោយឡែក ចំពោះផលិតកម្មភាពយន្តបរទេស ដែលបានផ្ដល់សិទ្ធិបញ្ចាំងខ្សែភាពយន្ត ជូនដល់រោងភាពយន្តក្នុងស្រុក ឬភ្នាក់ងារចែកចាយបន្ត នៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺត្រូវជាប់កាតព្វកិច្ចពន្ធកាត់ទុក ១៤% លើសួយសារនៃទ្រព្យអរូបី (ការផ្ដល់សិទ្ធិបញ្ចាំងខ្សែភាពយន្ត) ផ្អែកតាមមាត្រា ២៦ (ថ្មី) នៃច្បាប់ស្ដីពីសារពើពន្ធ។

#### ខ. ភ្នាក់ងារចែកចាយបន្តក្នុងស្រុក (Local agent) ឬរោងភាពយន្តក្នុងស្រុក (Local cinema)

ភ្នាក់ងារចែកចាយបន្ត និងរោងភាពយន្តក្នុងស្រុក ដែលទទួលបានសិទ្ធិពីម្ចាស់ខ្សែភាពយន្តនៅបរទេស ត្រូវមានកាតព្វកិច្ចកាត់ទុកពន្ធកាត់ទុក ១៤% លើសួយសារនៃទ្រព្យអរូបី (ការផ្ដល់សិទ្ធិបញ្ចាំងខ្សែភាពយន្ត)នៅពេលទូទាត់។ ដោយឡែក ការបង់កម្រៃនៃការផ្ដល់សិទ្ធិឱ្យបញ្ចាំងខ្សែភាពយន្តរបស់រោងភាពយន្តក្នុងស្រុក (Local cinema) ជូនដល់ភ្នាក់ងារចែកចាយបន្តក្នុងស្រុក គឺមិនត្រូវបានចាត់ទុកថាជាការបង់សួយសារដែលជាកម្មវត្ថុនៃពន្ធកាត់ទុកឡើយ ព្រោះភ្នាក់ងារចែកចាយបន្ត (Local agent) មិនមែនជាម្ចាស់កម្មសិទ្ធិដើមនៃទ្រព្យអរូបី (សិទ្ធិបញ្ចាំងខ្សែភាពយន្ត)ឡើយ។



អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

## ២. អំពីភាតព្វកិច្ចពន្ធកាត់ទុកចំពោះអាជីវកម្មជួលអចលនទ្រព្យបន្ត

ក្រុមហ៊ុនដែលធ្វើអាជីវកម្មជួលអចលនទ្រព្យបន្ត (Real Estate Company) នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានកាតព្វកិច្ចកាត់ទុកពន្ធកាត់ទុក ១០% នៅពេលទូទាត់ថ្លៃឈ្នួលអចលនទ្រព្យទៅឱ្យម្ចាស់ដើមនៃអចលនទ្រព្យ និងត្រូវប្រកាសបង់ពន្ធជូនរដ្ឋបាលសារពើពន្ធតាមច្បាប់ជាធរមាន។ ដោយឡែក ក្នុងករណីក្រុមហ៊ុនធ្វើអាជីវកម្មជួលអចលនទ្រព្យ (Real Estate Company) ជួលអចលទ្រព្យបន្តជូនដល់អតិថិជនរបស់ខ្លួនដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសគឺពុំតម្រូវឱ្យអតិជននោះកាត់ទុកពន្ធកាត់ទុកម្តងទៀតឡើយ ដោយអនុញ្ញាតឱ្យមានការកាត់ទុកលើថ្លៃឈ្នួលតែមួយលើកប៉ុណ្ណោះ គឺនៅពេលដែលក្រុមហ៊ុនជួលអចលនទ្រព្យ (Real estate company) ទូទាត់ថ្លៃឈ្នួលអចលនទ្រព្យទៅឱ្យម្ចាស់ដើមនៃអចលនទ្រព្យ។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹម និងជឿជាក់ថា សហគ្រាសដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ ពិតជាយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ។

ប្រតិភូរាជរដ្ឋាភិបាល

ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល